ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧
# ថ្ងៃសុក្រ ទី១៦ ខែមករា ឆ្នាំ២០២៦

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង ៨:០០នាទី រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៥ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ដោយមានវត្តមានសមាជិក សមាជិការដ្ឋសភា ពេលផ្ដើមសម័យប្រជុំចំនួន ១១៤រូប។

អង្គសភាបានអនុម័តយល់ព្រមរបៀបវារៈសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ចំនួន១ ដោយទទួលបានចំនួន **១១៤ សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

អង្គសភាបានបន្តនីតិវិធី ទៅតាមរបៀបវារៈ នៃសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ដោយមានការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ ។

សេចក្ដីព្រាងច្បាប់ស្ដីពី «ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ» មានភ្ជាប់ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ មានចំនួន ១៧ជំពូក ចែកជា ៣២០មាត្រា និងឧបសម្ព័ន្ធចំនួន៩ ដែលកម្ពុជា បានចុះហត្ថលេខា នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៨៣។

ការផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ នឹងផ្ដល់អត្ថប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជាដែលជាប្រទេសមានសមុទ្រ ដូចខាងក្រោម៖

- ទទួលបាននូវក្របខ័ណ្ឌច្បាប់សមុទ្រមួយពេញលេញ សម្រាប់កិច្ចការសមុទ្រក្នុងនាមជាប្រទេសជាប់សមុទ្រ
- ទទួលបានការការពារតាមច្បាប់សមុទ្រអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងសមុទ្ររបស់កម្ពុជា ដូចជាការគ្រប់គ្រងនិងការអភិរក្សបរិស្ថានសមុទ្រ ការធ្វើអាជីវកម្មលើធនធានសមុទ្រ និងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រជាដើម



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

- ពង្រឹងតួនាទីកម្ពុជាលើឆាកអន្តរជាតិ តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការដោយស្មើមុខ ក្នុងការគ្រប់គ្រងសមុទ្រនិងការដោះស្រាយបញ្ហាសមុទ្រជាមួយបណ្តាប្រទេសនានា និងមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសសមាសភាពអាជ្ញាធរបាតសមុទ្រអន្តរជាតិ រួមនឹងចៅក្រមតុលាការអន្តរជាតិនីតិសមុទ្រ

- ទទួលបាននូវកិច្ចសហប្រតិបត្តិការ និងជំនួយការបច្ចេកទេស រួមទាំងជំនួយការផ្នែកច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងការការពារ និងការអភិរក្សបរិស្ថានសមុទ្រ និងការផ្ទេរបច្ចេកវិទ្យាពីរដ្ឋភាគី និងស្ថាប័នអន្តរជាតិនានា ពាក់ព័ន្ធនឹងអនុសញ្ញានេះ

សេចក្តីព្រាងច្បាប់ស្តីពី «ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ» មាន ៣ មាត្រា។

**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង **ឯកឧត្តម ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុក រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជាតំណាងរាជរដ្ឋាភិបាល និងសហការី ជាអ្នកការពារសេចក្តីព្រាងច្បាប់។

អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន **១១៤សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ បានពិភាក្សា និងអនុម័តនូវរបៀបវារៈទី១០ ចប់សព្វគ្រប់ នៅវេលាម៉ោង ០៨:៣៥នាទី នាថ្ងៃខែឆ្នាំដដែល។ អាស្រ័យដោយអង្គសភា មិនទាន់មានរបៀបវារៈ សម្រាប់ធ្វើការពិភាក្សា និងអនុម័តបន្ត អង្គសភាបានលើកសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៧ មួយរយៈពេលសិន។

បំពោះព័ត៌មានទាក់ទងនឹងការបន្តសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ នឹងជម្រាបជូន និងទូលថ្វាយនៅពេលក្រោយតាមរយៈលិខិតអញ្ជើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**